**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ៧២៥/១៥ ក.អ.ជ.ប្រក

ថ្ងៃសុក្រ ៧ រោច ខែភទ្របទ ឆ្នាំមមី ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា គ.ស ២០១៥

# ប្រកាស

## ស្តីពី

## ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីនៃគណៈកម្មាធិការគ្រប់គ្រង មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តកំពង់ចាម

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងប្រកាសលេខ ០២៩៧ / ១០ ក.អ.ជ ប្រ.ក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តកំពង់ចាម
- យោងសំណើរបស់ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

## សម្រេច

**ប្រការ ១ .–** សម្រួលភារកិច្ចមន្ត្រី ០២ រូប ពីសមាសភាពគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តកំពង់ចាម មានដូចខាងក្រោម ÷

១. លោកស្រី ឃឹម លំអង ប្រធានផ្នែករដ្ឋបាល

២. លោក ឆែម ឡាង ប្រធានផ្នែកបច្ចេកទេស

**ប្រការ ២ .–** តែងតាំងមន្ត្រី ០២ រូប ជំនួសក្នុងសមាសភាពគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តកំពង់ចាម មានដូចខាងក្រោម ÷

១. កញ្ញា សេន ស្រីល័ក្ខ ជាប្រធានផ្នែករដ្ឋបាល

២. លោក ឃឹម សុង ជាប្រធានផ្នែកបច្ចេកទេស

**ប្រការ ៣ .–** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ ១ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ជា សុផារ៉ា**

<u>កន្លែងទទួល</u>÷

- សាលាខេត្តកំពង់ចាម

  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ ១, ២ និង ៣

  *"ដើម្បីអនុវត្ត"*
- ឯកសារ កាលប្បវត្តិ